**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
លេខ ៩១២.០២៥.៨០៥.ស.ក.ណ

ថ្ងៃច័ន្ទ ១២រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នឹងធ្វើការជ្រើសរើសបុគ្គលិកទាំងពីរភេទ ដើម្បីចូលបម្រើការងារ ដោយបេក្ខជនត្រូវមានលក្ខណៈសម្បត្តិនិងបំពេញលក្ខខណ្ឌនៃការជ្រើសរើសដូចខាងក្រោម៖

I/- **ក្របខ័ណ្ឌមន្ត្រីក្រមការ "ខ"** ចំនួន ៥រូប ៖

- មានសញ្ជាតិខ្មែរ
- មានអាយុច្រើនបំផុត ៣០ឆ្នាំ គិតត្រឹមថ្ងៃឈប់ទទួលពាក្យ
- មានសញ្ញាបត្របរិញ្ញាបត្រផ្នែកច្បាប់ ឬបរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា ឬបរិញ្ញាបត្រផ្នែកធនាគារនិងហិរញ្ញវត្ថុ
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ដូចជា សញ្ញាបត្រភាសាអង់គ្លេស កម្រិត IELTS ៥.៥ ឡើងទៅ ឬកម្រិតប្រហាក់ប្រហែល និង
- មានចំណេះដឹង និងបទពិសោធការងារពាក់ព័ន្ធ។

II/- **ក្របខ័ណ្ឌលេខាធិការ "គ"** ចំនួន ១០រូប ៖

- មានសញ្ជាតិខ្មែរ
- មានអាយុច្រើនបំផុត ២៥ឆ្នាំ គិតត្រឹមថ្ងៃឈប់ទទួលពាក្យ
- មានសញ្ញាបត្រប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ដូចជា កម្រិត IELTS ៥.០ ឡើងទៅ ឬកម្រិតប្រហាក់ប្រហែល និង
- មានចំណេះដឹង និងបទពិសោធការងារពាក់ព័ន្ធ។



ប្រអប់សំបុត្រលេខ ៥៤ ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ cafiu.nbc.gov.kh cafiu_info@nbc.gov.kh

បេក្ខជនដែលមានចំណាប់អារម្មណ៍ ត្រូវបំពេញពាក្យស្នើសុំតាមរយៈការស្កេន QR Code ដែលភ្ជាប់មកខាងក្រោម ឬតាមរយៈគេហទំព័រ https://recruitment.nbc.gov.kh ឬទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមតាមរយៈលេខទូរសព្ទ ០២៣ ៧២២ ២២១/ ០៨១ ៨៧៧ ២២៧។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ **ថ្ងៃពុធ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ១១:០០នាទីព្រឹក**
- កាលបរិច្ឆេទប្រឡង ៖ ជូនដំណឹងពេលក្រោយ ។

**ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

ហេង បូមករា

សូមស្កេនដើម្បីបំពេញ
បែបបទដាក់ពាក្យស្នើសុំប្រឡង